# ផ្តាច់ទៅតាមរបៀបផ្ទាល់ខ្លួនរបស់អ្នក

QUITPLAN® ផ្តល់ជូនដល់អ្នករស់នៅរដ្ឋ Minnesotaទាំងឡាយនូវជំនួយ ឥតគិតថ្លៃដើម្បីផ្តាច់ការប្រើប្រាស់ថ្នាំជក់។ គោលបំណងរបស់យើងគឺ មានលក្ខណៈសាមញ្ញណាស់ ៖ គឺដើម្បីធ្វើអ្វីៗគ្រប់យ៉ាងដែលយើងអាចដើម្បីជួយអ្នកយ៉ាងណាឱ្យផ្តាច់ពីថ្នាំជក់បាន 100 ភាគរយ ។ មិនមែនដោយការបង្រៀន ប៉ុន្តែដោយការគាំទ្រពិតប្រាកដ និងអ្វីផ្សេងៗទៀតដែលអាចឲ្យអ្នកផ្តាច់បានតាមរបៀបផ្ទាល់ខ្លួនរបស់អ្នក។

**សូមជ្រើសយកសេវា QUITPLAN®ទាំងឡាយដែលត្រឹមត្រូវសម្រាប់អ្នក។**
មិនថានៅចំណុចណាដែលអ្នកស្ថិតនៅ នៅក្នុងដំណើរការផ្តាច់ឡើយ អ្នកអាចជ្រើសរើសយកសេវា QUITPLAN មួយ ឬទាំងអស់ ឬជ្រើសរើសយកការទូរស័ព្ទតាមខ្សែទូរស័ព្ទជំនួយ QUITPLAN។

ដើម្បីស្វែងយល់បន្ថែម សូមទូរស័ព្ទទៅលេខ 1-888-354-7526 ឬចូលមើល quitplan.com

ប្រសិនបើអ្នកចង់និយាយទៅកាន់គ្រូបង្វឹកដោយប្រើអ្នកបកប្រែភាសា សូមទូរស័ព្ទទៅលេខ 1-888-354-7526 ហើយសុំរក អ្នកបកប្រែភាសាដែលអ្នកនិយាយ នៅពេលដែលអ្នកទូរស័ព្ទទៅ។ បុគ្គលិកទាំងឡាយរបស់សេវា QUITPLAN មានបទពិសោធន៍ក្នុងការជួយមនុស្សមកពីគ្រប់ជាតិសាសន៍ ជនជាតិ និងអ្នកមានប្រវត្តិមកពីវប្បធម៌ណាៗទាំងអស់ ។ គេហទំព័រ quitplan.com មានប៊ូតុង Google Translate ដែលអាចប្រើបានដើម្បីបកប្រែវិបសៃត៍នេះ។

## គ្មានការវិនិច្ឆ័យលើរូបអ្នកឡើយ។ គឺត្រឹមតែជួយសុទ្ធសាធ។



## ការចាប់ផ្តើមជាមួយសេវា QUITPLAN® គឺមានលក្ខណៈសាមញ្ញណាស់។

សូមទូរស័ព្ទមកយើងខ្ញុំតាមទូរស័ព្ទលេខ 1-888-354-7526 ដើម្បីចុះឈ្មោះទទួលសេវាកម្មណាមួយក្នុងចំណោមសេវាកម្មនានារបស់យើង។ អាចទាក់ទងបាន 24ម៉ោងក្នុងមួយថ្ងៃ 7ថ្ងៃក្នុងមួយសប្តាហ៍។

សូមរួសរាន់ចុះឈ្មោះ សម្រាប់សេវាកម្មណាមួយរបស់យើងតាមបណ្តាញអ៊ីនធឺណិត តាម quitplan.com។

តើមិនទាន់ចុះឈ្មោះនៅឡើយទេឬ? សូមចូលទៅមើលវិបសៃត៍ quitplan.com ដើម្បីមើលការផ្តល់យោបល់គន្លឹះ និងអ្វីៗផ្សេងៗ (tools) និងព័ត៌មានដើម្បីជួយអ្នកផ្តាច់បានទៅតាមរបៀបផ្ទាល់ខ្លួនរបស់អ្នក។

QUITPLAN®

1-888-354-7526
quitplan.com

# ផ្តាច់ទៅតាមរបៀបផ្ទាល់ខ្លួនរបស់អ្នក

ប្រសិនបើអ្នកកំពុងគិតចង់ផ្តាច់ការប្រើប្រាស់ថ្នាំជក់ សេវា QUITPLAN ផ្តល់អ្វីផ្សេងៗ និងជំនួយដោយឥតគិតថ្លៃដើម្បីជួយអ្នកបង្កើតគម្រោងដែលធ្វើឱ្យអ្នកអាចផ្តាច់បានទៅតាមរបៀបផ្ទាល់ខ្លួនរបស់អ្នក។ ប្រសិនបើអ្នកចង់និយាយជាមួយសេវា QUITPLAN ដោយប្រើអ្នកបកប្រែ សូមទូរស័ព្ទទៅលេខ 1-888-354-7526 ហើយសួររកអ្នកបកប្រែភាសាដែលអ្នកនិយាយ នៅពេលអ្នកទូរស័ព្ទទៅ។

## សេវា QUITPLAN® សម្រាប់បុគ្គល

កម្មវិធីដែលរៀបចំឡើងតម្រូវទៅតាមតម្រូវការរបស់អ្នក។ ចុះឈ្មោះសម្រាប់សេវាណាមួយឬសេវាទាំងអស់របស់ QUITPLAN សម្រាប់បុគ្គល ដែលមានរាយដូចខាងក្រោម។

**ការផ្ញើសារអត្ថបទ***
ទទួលព័ត៌មានជំនួយ ហ្គេម និងការក្រើនរំឭក។ កម្មវិធី Text2Quit℠ គឺពោរពេញទៅដោយដំបូន្មានជាក់ស្តែង និងការលើកទឹកចិត្តដែលជួយឲ្យអ្នកអាចផ្តាច់វា។

**កញ្ចប់បរិក្ខាសម្រាប់អ្នកចាប់ផ្តើម៖**
ប្លាក ស្ករកៅស៊ូ ឬ តុលិកា(LOZENGES)
ទទួលបានប្លាក ស្ករកៅស៊ូ ឬតុលិកា(Lozenges)ឥតគិតថ្លៃរយៈកាលពីរសប្តាហ៍ដើម្បីជួយអ្នកចាប់ផ្តើម។

**កម្មវិធីតាមអ៊ីម៉ែល***
ទទួលស៊េរីនៃអ៊ីម៉ែលមួយដែលពេញទៅដោយយោបល់ជំនួយ ដំបូន្មាន និងការលើកទឹកចិត្ត ដើម្បីជួយអ្នកផ្តាច់(ថ្នាំជក់)។

**ការណែនាំពីការផ្តាច់***
ពីការផ្តាច់ជាក់ស្តែង និងមានសារៈប្រយោជន៍ ដើម្បីជួយអ្នកក្នុងការបង្កើតគម្រោងផ្តាច់របស់អ្នក។ អ្នកអាចជ្រើសរើស ទាញយក(Download)វា ឬឱ្យគេផ្ញើសំបុត្រតាមប្រៃសណីយ៍ឱ្យអ្នក។

## QUITPLAN®

កម្មវិធីពេញលេញមួយ។ អ្នកនឹងទទួលបានការផ្តល់មេរៀនតាមទូរស័ព្ទមួយទល់មួយជាមួយនឹងអ្នកប្រឹក្សាផ្តល់យោបល់ពីរឿងថ្នាំជក់ដែលមានការបណ្តុះបណ្តាល និងអ្វីៗផ្សេងៗបន្ថែមទៀតដើម្បីជួយឲ្យអ្នកផ្តាច់វា។

**ការហ្វឹកហាត់តាមទូរស័ព្ទ**
មេរៀនមួយទល់មួយចំនួនប្រាំជាមួយគ្រូបង្វឹកពីការផ្តាច់ ដើម្បីជួយអ្នកស្វែងយល់ និងប្រើយុទ្ធសាស្រ្តផ្សេងៗដើម្បីជួយអ្នកផ្តាច់(ថ្នាំជក់)។

**ការផ្ញើសារអត្ថបទ***
ទទួលព័ត៌មានជំនួយ ហ្គេម និងការក្រើនរំឭកប្រចាំថ្ងៃ។ កម្មវិធី Text2Quit℠ ក៏ផ្តល់ច្រករហ័សទៅកាន់គ្រូបង្វឹកបន្ថែមលើការតាមដានការផ្តាច់ ការសន្សំសំចៃការប្រើប្រាស់ និងការឃ្លានចង់ថ្នាំជក់របស់អ្នក។

**ប្លាក ស្ករកៅស៊ូ ឬតុលិកា(LOZENGES)**
ទទួលបានប្លាក ស្ករកៅស៊ូ ឬតុលិកាឥតគិតថ្លៃរយៈកាលបួនសប្តាហ៍តាមរយៈបណ្តាញជំនួយ QUITPLAN។

**ផ្នែកគាំទ្រតាមអ៊ីម៉ែល***
អ៊ីម៉ែលតម្រូវតាមបុគ្គលស្តីពីកាលបរិច្ឆេទផ្តាច់របស់អ្នក ការហ្វឹកហាត់តាមទូរស័ព្ទ និងព្រឹត្តិការណ៍សំខាន់ៗនៃការផ្តាច់ ព្រមទាំងយោបល់ជំនួយមានប្រយោជន៍ ដំបូន្មាន និងការលើកទឹកចិត្ត។

**កញ្ចប់ស្វាគមន៍ដែលមានគ្រឿងបរិក្ខានានា***
រួមមានសៀវភៅណែនាំពីការផ្តាច់ដែលបោះពុម្ព និងឯកសារចែកជូនបន្ថែមដែលនឹងជួយអ្នកបង្កើតគម្រោងផ្ទាល់ខ្លួនរបស់អ្នកដើម្បីផ្តាច់។

*អាចរកបានជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញប៉ុណ្ណោះ

QUITPLAN®

1-888-354-7526
quitplan.com